# សេចក្តីប្រកាសពត៌មាន

នៅថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០០៨ អង្គបុរេជំនុំជម្រះបានចេញនូវសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនិងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេត ដែលបានចោទប្រកាន់លើឈ្មោះ **កាំង ហ្គេកអ៊ាវ** ហៅ **ឌុច** ។ ក្រោយពីអង្គជំនុំជម្រះសាលាដំបូងបានទទួលនូវសំណុំរឿងក្តីនេះរួចហើយ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អ.វ.ត.ក សូមផ្តល់នូវពត៌មានមួយចំនួនដូចខាងក្រោមទាក់ទងទៅនិងដំណាក់កាលនានានៃកិច្ច ដំណើរការនីតិវិធី ៖

១. យោងទៅតាមវិធាន ៨០ នៃវិធានផ្ទៃក្នុង សហព្រះរាជអាជ្ញាត្រូវដាក់ជូននូវបញ្ជីឈ្មោះសាក្សី និងអ្នកជំនាញដែលខ្លួនមានបំណងកោះហៅ ក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃមកអង្គជំនុំជម្រះសាលាដំបូង។ គិតចាប់ពីថ្ងៃទទួលដំណឹងនៃបញ្ជីឈ្មោះសាក្សីនិងអ្នកជំនាញ ជនជាប់ចោទ និង/ឬ ដើមបណ្តឹងរដ្ឋប្បវេណីក៏មានរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ ដើម្បីដាក់ជូនបញ្ជីឈ្មោះបន្ថែមនូវសាក្សី និងអ្នកជំនាញ ។

២. ដើម្បីសម្របសម្រួលដល់ការប្រព្រឹត្តិទៅនៃកិច្ចដំណើរការនីតិវិធីប្រកបដោយយុត្តិធម៌ និង ឆាប់រហ័ស អង្គជំនុំជម្រះសាលាដំបូងនឹងរៀបចំឲ្យមាននូវការប្រជុំរៀបចំសវនាការ ដើម្បីអនុញ្ញាតឲ្យមានការផ្លាស់ប្តូរមតិយោបល់គ្នារវាងភាគីទាំងឡាយ ដើម្បីសម្របសម្រួលការកំណត់កាលបរិច្ឆេទនៃការធ្វើសវនាការបឋម និងសវនាការនៃអង្គសេចក្តី និងដើម្បីពិនិត្យឡើងវិញនូវរឿងក្តី ។ កិច្ចប្រជុំ នេះត្រូវបានកំណត់ថានឹងធ្វើឡើងនៅថ្ងៃទី ១៥ និង ១៦ ខែ មករា ឆ្នាំ ២០០៩ ។ កិច្ចប្រជុំនេះត្រូវធ្វើ ឡើងជាអសាធារណៈ។ (វិធាន ៧៩(៧))

៣. ក្រោយពីកិច្ចប្រជុំរៀបចំសវនាការខាងលើ ប្រធានអង្គជំនុំជម្រះសាលាដំបូងនឹងកំណត់នូវ កាលបរិច្ឆេទសវនាការបឋម ដែលក្នុងពេលនោះអង្គជំនុំជម្រះសាលាដំបូងត្រូវពិចារណាអំពីបញ្ជី ឈ្មោះសាក្សីនិងអ្នកជំនាញដែលដាក់ជូនដោយភាគី ពិចារណាអំពីអញ្ញត្រកម្មនិងបណ្តឹងសុំតាំងខ្លួនជា ដើមបណ្តឹងរដ្ឋប្បវេណីដោយជនរងគ្រោះ ។ ដូចគ្នានេះផងដែរ អង្គជំនុំជម្រះសាលាដំបូងសូមបញ្ជាក់ ថា វិធាន ២៣ អនុវិធាន ៤ បានកំណត់នូវរយៈពេលសម្រាប់ការដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី៖ ដើម្បីអាចទទួលយកបាន ពាក្យស្នើសុំត្រូវដាក់នៅអង្គភាពជនរងគ្រោះយ៉ាងតិចរយៈពេល ១០ (ដប់) ថ្ងៃនៃថ្ងៃការងារមុនកាលបរិច្ឆេទនៃសវនាការបឋម

ប្រធានអង្គជំនុំជម្រះនឹងមិនប្រើនូវសិទ្ធិរបស់គាត់ក្នុងការពន្យា ឬកាត់បន្ថយរយៈពេលកំណត់ខាងលើនេះទេ ។ កាលបរិច្ឆេទនឹងត្រូវកំណត់ក្នុងសេចក្តីសម្រេចស្តីពីការកំណត់កាលបរិច្ឆេទសវនាការបឋម។

៤. កាលបរិច្ឆេទនៃសវនាការអង្គសេចក្តីនឹងត្រូវកំណត់ បន្ទាប់ពីការបញ្ចប់នូវសវនាការបឋម ។